ម៉ូរីសុនកាក់ អិមខេអេ
Morisonkak MKA
Certified Public Accountants, Since 1996

# សេចក្តីជូនដំណឹង
## ស្តីពី វឌ្ឍនភាពនៃការជម្រះបញ្ជី
## ធនាគារ ព្រីនស៍ ម.ក និង ធនាគារ ផេនដា ខមមើសល បែ៊ង ម.ក

ក្រុមហ៊ុន ម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក ក្នុងនាមអ្នកជម្រះបញ្ជីដែលត្រូវបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា ដំណើរការជម្រះបញ្ជី ធនាគារ ព្រីនស៍ ម.ក និង ធនាគារ ផេនដា ខមមើសល បែ៊ង ម.ក ប្រព្រឹត្តទៅដោយតម្លាភាព វិជ្ជាជីវៈ និងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ គិតត្រឹមថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៦ វឌ្ឍនភាពការងារសំខាន់ៗរួមមាន៖

១. ការជម្រះបញ្ជី ធនាគារ ព្រីនស៍ ម.ក

អ្នកជម្រះបញ្ជីបានទូទាត់ម្ចាស់ប្រាក់បញ្ញើស្ទើរតែទាំងស្រុង លើកលែងតែ ប្រាក់បញ្ញើដែលត្រូវបានបង្កកដោយស្ថាប័នតុលាការ និងប្រាក់បញ្ញើមានទឹកប្រាក់តូចៗដែលម្ចាស់ប្រាក់បញ្ញើមិនទាន់បានមកទទួល ឬមិនអាចទាក់ទងបានតែប៉ុណ្ណោះ។ ទន្ទឹមនេះ អ្នកជម្រះបញ្ជីក៏កំពុងបន្តផ្ទេរសិទ្ធិលើឥណទានរបស់អតិថិជននៃធនាគារ ព្រីនស៍ ម.ក ទៅ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ស្របតាមសេចក្តីជូនដំណឹងចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៦។

២. ការជម្រះបញ្ជី ធនាគារ ផេនដា ខមមើសល បែ៊ង ម.ក

អ្នកជម្រះបញ្ជីកំពុងបន្តបំប្លែងទ្រព្យសកម្មរបស់ធនាគារទៅជាសាច់ប្រាក់ ដើម្បីទូទាត់ជូនម្ចាស់ប្រាក់បញ្ញើនិងបំណុល។ ដោយសារការបំប្លែងទ្រព្យសកម្មត្រូវការពេលវេលា ការទូទាត់ប្រាក់បញ្ញើត្រូវបានអនុវត្តជាដំណាក់កាល។ តាមការគ្រោងទុក ម្ចាស់ប្រាក់បញ្ញើប្រមាណ ៩៦% នឹងទទួលបានការទូទាត់ទាំងស្រុង ក្នុងដំណាក់កាលទី១។ បច្ចុប្បន្ននេះ សម្រាប់ដំណាក់កាលទី១ អ្នកជម្រះបញ្ជីកំពុងបន្តបើកប្រាក់ជូនម្ចាស់ប្រាក់បញ្ញើតាមលំដាប់លេខរៀង។ ក្នុងន័យនេះ សូមលើកទឹកចិត្តដល់ម្ចាស់ប្រាក់បញ្ញើដែលមិនទាន់បានមកបើកប្រាក់ក្នុងដំណាក់កាលទី១ ត្រៀមឯកសារពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ និងអញ្ជើញមកបើកប្រាក់របស់ខ្លួន។ ដោយឡែក ចំពោះម្ចាស់ប្រាក់បញ្ញើដែលមានទឹកប្រាក់ចាប់ពី ១ ដុល្លារអាមេរិក ដល់ ៥០០ ដុល្លារអាមេរិក សូមអញ្ជើញមកបើកប្រាក់ក្នុងរយៈពេលមិនលើសពី ១ ខែ គិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ ការជូនដំណឹងនេះចាត់ទុកជាការរំលឹកលើកទី១ ដល់ម្ចាស់ប្រាក់បញ្ញើពាក់ព័ន្ធដើម្បីអញ្ជើញមកបើកប្រាក់របស់ខ្លួនឱ្យបានទាន់ពេលវេលា។

ចំណែកម្ចាស់ប្រាក់បញ្ញើចំនួន ១៩៨ នាក់ (ម្ចាស់ប្រាក់បញ្ញើដែលមានទឹកប្រាក់ធំ) ដែលមិនទាន់ទូទាត់បានទាំងស្រុងនៅឡើយ អ្នកជម្រះបញ្ជីនឹងបន្តទូទាត់នៅដំណាក់កាលបន្ទាប់ ស្របតាមវឌ្ឍនភាព នៃការបំប្លែងទ្រព្យសកម្ម។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងក្រុមការងារជម្រះបញ្ជី តាមរយៈទូរសព្ទ៖ ០១៨ ២៨២ ៨៨៣៥ និង ០១៨ ២៨២ ៨០០១។

អាស្រ័យហេតុនេះ សូមម្ចាស់ប្រាក់បញ្ញើរបស់ធនាគារ ព្រីនស៍ ម.ក និង ធនាគារ ផេនដា ខមមើសល បែ៊ង ម.ក និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦
ក្រុមហ៊ុន ម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក

MORISONKAK MKA AUDIT - ACCOUNTING CO., LTD.
No 10, Street 500, Sangkat Psar Deum Thkov, Khan Chamcarmon, Phnom Penh, Cambodia
Tel: +855 23 218 994 (3 lines) - Fax: +855 23 218 993 - Email: mka.audit@morisonkak.com
Email: mka.management@morisonkak.com - Website: www.morisonkak.com

Independent member
Morison Global